

# មង្គលការរបស់កញ្ជ្រោង

Chhabilal Kopila

Suman Maharjan

Let's Read

The Asia Foundation



នៅក្នុងព្រៃមួយភាគខាងជើងភូមិ មានសត្វកញ្ជ្រោងកំពុង
រស់នៅ។ វាកំពុងព្រួយបារម្ភជាខ្លាំងពីពិធីមង្គលការកូនប្រុស
របស់វា។



ថ្ងៃមួយ ទន្សាយដែលជាមិត្តសម្លាញ់របស់វា បានផ្ដល់យោបល់ថា «ពួកយើងគួរតែពិគ្រោះជាមួយនឹងអ្នកភូមិ។»



កញ្ជ្រោងយល់ស្របនឹងគំនិតរបស់ទន្សាយ។ វាបានស្នើឱ្យឆ្កែទៅអញ្ជើញសត្វដទៃទៀតមកចូលរួម។ ឆ្កែបានទៅផ្ទះសត្វផ្សេងៗនៅក្នុងព្រៃ ហើយសុំឱ្យមកប្រជុំគ្នានៅផ្ទះរបស់កញ្ជ្រោង។



នៅពេលដែលបក្សី និងសត្វពាហនៈនៅក្នុងព្រៃទាំងអស់
បានមកដល់ កញ្ច្រោងបាននិយាយថា«ខ្ញុំត្រូវការរៀបចំពិធី
មង្គលការកូនប្រុសរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចធ្វើវាដោយខ្លួនឯង
បានទេ។ តើអ្នកទាំងអស់គ្នាអាចជួយខ្ញុំបានទេ?»



ក្អែកបានស្ទុះងើបភ្លាមហើយនិយាយថា«ខ្ញុំនឹងជួយអញ្ជើញ
ភ្ញៀវ!»
សារិកាកែវបានច្រៀងថា «សំឡេងរបស់ខ្ញុំពីរោះបំផុត អ៊ីចឹងខ្ញុំ
នឹងជួយទទួលភ្ញៀវ។»



ឱម៉ាល់ លើកដៃហើយបានស្នើថា «ខ្ញុំនឹងទទួលបន្ទុកខាងតុបតែងកន្លែងពិធី។ ខ្ញុំនឹងលាបពណ៌ផ្ទះឡើងវិញ ហើយរៀបចំវាឱ្យបានស្អាត។»



ក្ងោកត្រដាងកន្ទុយដ៏ស្រស់ស្អាតរបស់ខ្លួន រួចនិយាយថា « ខ្ញុំ
អាចរាំកំដរបរិយាកាស ហើយធ្វើឱ្យគ្រប់គ្នាសប្បាយរីករាយ។»



ស្រមោចបានបង្អួតសាច់ដុំហើយបោះជំហានទៅមុខដោយប្រកាសថា«ខ្ញុំនឹងទទួលខុសត្រូវលើការដឹកជញ្ជូន។»



មេមាន់ស្រែកក្រូកៗថា« ខ្ញុំទទួលខុសត្រូវលើផ្នែកម្ហូបអាហារ ។»



សត្វជន្លេនបានវារចេញពីក្នុងដីមក ហើយបាននិយាយថា« ខ្ញុំនឹងទទួលខុសត្រូវបំពេញចន្លោះប្រហោងទាំងឡាយ។»
ស្របពេលជាមួយគ្នានោះ សត្វកង្កែបបានដេកលក់នៅឯជ្រុងម្ខាង។



សត្វស្រមោចបានចាក់ក្រឡៀកសត្វកង្កែប។



ថ្ងៃមង្គលការបានខិតជិតមកដល់ហើយ។ ក្អែកបានហោះហើរចេញទៅជាមួយនឹងលិខិតអញ្ជើញ។

ផ្កានានាត្រូវបានចងភ្ជាប់នៅជុំវិញរបង។ ពន្លឺភ្លើងក៏បានបញ្ចេញពន្លឺភ្លឺបភ្លែតគ្រប់ទីកន្លែងដែរ។ ការរៀបចំសម្រាប់ពិធីមង្គលការបានរួចរាល់ជាស្រេចហើយ។



ភ្ញៀវកិត្តិយសទាំងឡាយបានមកដល់។ ឆ្មាបានមកដល់មុនគេបង្អស់។ បន្ទាប់មកក៏ចាប់ផ្ដើមការច្រៀងរាំ។ ពិធីដល់ពេលចាប់ផ្ដើមហើយ។ សត្វកង្កែបដកដង្ហើមធំមួយដើម្បីត្រៀមខ្លួនច្រៀងចម្រៀង។ ប៉ុន្តែជំនួសដោយចម្រៀងថ្ងៃមង្គល កង្កែបបែរជាច្រឡំច្រៀងបទចម្រៀងហៅទឹកភ្លៀងទៅវិញ។
សូមឱ្យមានពពកខ្មៅដេរដាស មេឃឈប់ស្រឡះមានតែទឹកភ្លៀង ធ្លាក់មកឱ្យសើមគ្រប់ទីកន្លែង ខ្ញុំលែងចំបែងព្រោះមានទឹកភ្លៀង។



ប្រាកដណាស់ ក្រោយពេលកង្កែបស្រែកច្រៀង ពពកខ្មៅក៏បាន លេចឡើង ហើយភ្លៀងក៏ធ្លាក់មកយ៉ាងជោគជាំ។ កញ្ជ្រោងក៏ភ័យស្លន់ស្លោ។



កង្កែបដឹងកំហុសរបស់ខ្លួន។ វាសម្រួលបំពង់ក ហើយច្រៀងបទចម្រៀងដែលត្រូវវិញ។

សក្រវាទី៏ ផ្កាម្រុំ មួយរោចខែភ្ជុំយើងនាំគ្នារៀបការ។ហើយម្ដាយកូនកំលោះក៏បាននាំកូនកំលោះចេញមក។



មិនយូរប៉ុន្មាន ព្រះអាទិត្យក៏រះមកវិញ ប៉ុន្តែមេឃនៅរលឹម
នៅឡើយ។ ភ្ញៀវក៏នាំគ្នាចាប់ផ្តើមរាំ។

## Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*गिद्रक भोज (A Fox's Wedding)*, Author: Chhabilal Kopila. Illustrator: Suman Maharjan. Published by The Asia Foundation - Let's Read,
© The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/